# លក្ខខន្តិកៈ

## ធានារ៉ាប់រងប៊ីម៉ា ម៉ូតូ

## នរណានឹងទទួលបានការធានា?

ធានារ៉ាប់រងប៊ីម៉ា ម៉ូតូ-ម្ចាស់បណ្ណ័សន្យារ៉ាប់រងត្រូវតែផ្តល់ ព័ត៏មានលម្អិតពីយានយន្ត នៅលើគោលការណ៍ដើម្បីទទួលបានការធានានេះ។

## អាយុ:

អ្នកត្រូវតែមានអាយុចន្លោះពី 18-60ឆ្នាំ(ទាំងពីរត្រូវបានរាប់បញ្ចូល)។

## ការកាត់ទឹកប្រាក់ និង ការធានា:

- លក្ខខណ្ឌនៃការប្រើប្រាស់ ដើម្បីទទួលបានការធានាត្រូវបង់បុព្វលាភជាសាច់ប្រាក់នៅពេលចុះឈ្មោះជាមួយមន្ត្រីផ្នែកលក់របស់យើង។
- អត្ថប្រយោជន៍ពេញលេញនឹងទទួលបានភ្លាមៗបន្ទាប់ពីធ្វើការចុះឈ្មោះ។

  ឧទាហរណ៍:បន្ទាប់ពីមានការបង់ទឹកប្រាក់បុព្វលាភពេញលេញរួចរាល់នៅថ្ងៃទី 20 ខែមករា ការធានានឹងមានសុពលភាពក្នុងថ្ងៃខែឆ្នាំដដែល ។ គ្មានការរង់ចាំដើម្បីទទួលបានការធានាលើផលិតផលនេះ។

## ការទាមទារសំណង:

ការទាមទារសំណង អាចធ្វើទៅបានក្នុងរយៈពេល 12ខែក្នុងករណីមានគ្រោះថ្នាក់កើតឡើង ។ ដំណើរការផ្តល់សំណងនឹងផ្តល់បន្ទាប់ពីទទួលបានឯកសារខាងក្រោមបានគ្រប់គ្រាន់៖

- ថតចម្លងឯកសារបញ្ជាក់អត្តសញ្ញាណ កាតគ្រី (ថតចម្លង) និងបណ្ណសមាជិកធានារ៉ាប់រងអ្នកដែលត្រូវបានធានា។
- ច្បាប់ថតចម្លងឯកសារបញ្ជាក់អត្តសញ្ញាណរបស់អ្នកដែលត្រូវទាមទារសំណង។
- របាយការណ៍ប៉ូលីស ឬអាជ្ញាធរមូលដ្ឋានដែលបញ្ជាក់ពីកាលបរិច្ឆេទ ប្រភេទគ្រោះថ្នាក់ដែលបានកើត ឡើង និងមូលហេតុនៃគ្រោះថ្នាក់ ឬការបាត់បង់ដោយចោរកម្ម។
- អតិថិជនអាចទំនាក់ទំនងមកក្រុមហ៊ុនប៊ីម៉ា តាមរយៈលេខទូរសព្ទ័ រឺក៏អាចមកក្រុមហ៊ុនផ្ទាល់ដើម្បីធ្វើការទាមទារសំណង។ មីលវីក(Milvik) នឹងធ្វើការផ្តល់សំណងយ៉ាងយូរបំផុតមិនឱ្យលើសពីរយៈពេល ៣ ថ្ងៃនៃថ្ងៃធ្វើការ ប្រសិនបើបានដាក់ឯកសារមកគ្រប់គ្រាន់ ។ ក្នុងករណីម្ចាស់បណ្ណ័សន្យារ៉ាប់រងទទួលមរណៈភាព សំណងនឹងត្រូវបានផ្តល់ជូនអ្នកទទួលផលសំណងដែលមានក្នុងគោលការណ៍ដោយផ្ទាល់ ។

## <u>ករណីលើកលែងមិនផ្តល់សំណង:</u>

ផលិតផលធានារ៉ាប់រង"ប៊ីម៉ា ម៉ូតូ" មានករណីមួយចំនួន ដែលមិនត្រូវបានធានា និងមិនអាចទទួលបានសំណងពី ក្រុមហ៊ុន មីលវីក ប្រសិនបើការខូតខាត ឬចោរកម្ម លើយានយន្តកើតឡើងបណ្តាលមកពីករណីរួមមានដូចខាងក្រោម

1. ការចូលរួម ឬប៉ុនប៉ងក្នុងការប្រព្រឹត្តនូវអំពើល្មើសច្បាប់ចរាចរណ៍ផ្លូវគោក នៃព្រះរាជាណាចក្រកម្ពុជា រាល់ពេលបើកបរយានយន្តដូចជា+ បណ្ណបើកបរផុតសុពលភាព ការបើកបរម៉ូតូដោយមិនពាក់មួកសុវត្ថិភាព ដែលការពារមិនបានត្រឹមត្រូវ និងអំពើណាមួយដែលត្រូវបានចាត់ទុកថាជាអំពើប្រព្រឹត្ត ផ្ទុយទៅនឹងច្បាប់ចរាចរណ៍ផ្លូវគោក និងច្បាប់ជាធរមានដទៃទៀត។
2. ផលប៉ះពាល់ទាំងឡាយ ដែលបណ្តាលមកពីការប្រើប្រាស់នូវគ្រឿងស្រវឹង ឬគ្រឿងញៀនលើសកម្រិត ដែលយោងទៅតាមច្បាប់ចរាចរណ៍ផ្លូវគោក នៃព្រះរាជាណាចក្រកម្ពុជា។
3. ការបង្កឡើងដោយចេតនា ឬការបង្កគ្រោះថ្នាក់ដោយចេតនា។
4. ផលប៉ះពាល់បណ្តាលមកពីការចូលរួមប្រព្រឹត្តបទល្មើស ដោយមិនកម្រិតត្រឹម បទមជ្ឈឹម ឬបទឧក្រិដ្ឋផ្សេងៗ (លួចឆក់ ប្លន់ជាដើម)។
5. ធ្វើការជួសជុល ដោយមិនបានផ្តល់ព័ត៌មាន ឬជូនដំណឹងដល់ក្រុមហ៊ុន មីលវីក ជាមុន។
6. ការប៉ះទង្គិច និងការខូចខាតដែលមិនបង្កឡើងដោយគ្រោះថ្នាក់ចៃដន្យ។
7. ការខូចខាត ឬការបាត់បង់ដែលកើតចេញពីការកិបកេងដោយកម្មសិទ្ធិករយានយន្ត ឬបណ្តាលមកពីទឹកជំនន់ សង្គ្រាម អំពើភេរវកម្ម នុយក្លេអ៊ែរ កូដកម្ម កុប្បកម្ម និងចលាចលស៊ីវិល។
8. បើកបរ ឬចតនៅកន្លែងដែលមានហានិភ័យខ្ពស់ ( ក្រោមចេតនាបង្ករឱ្យមានគ្រោះថ្នាក់ ឬងាយបង្ករឱ្យមាន ហានិភ័យ) ឬការខូចខាត ឬការបាត់បង់ ដែលបណ្តាលមកពីការធ្វេសប្រហែសដូចជា ករណីដើរចោលម៉ូតូដោយទុកសោរជាប់នៅនឹងម៉ូតូ (នៅតំបន់ដែលមមាញឹក ឬមនុស្សច្រើន) មាន ដែលមានដាក់បម្រាមហាមឃាត់ហើយបណ្តាលឱ្យមានឧប្បទ្ទវហេតុកើតឡើង។

## <u>ការលុបចោលការធានា:</u>

គោលការណ៍នៃការធានាអាចធ្វើការលុបចោលបានដោយធ្វើការទាក់ទងទៅកាន់ផ្នែកបម្រើសេវាអតិថិជនរបស់មីលវីក (Milvik) ឬមកកាន់ការិយាល័យក្រុមហ៊ុនមីលវីក(Milvik) ដើម្បីយកប្រាក់បង្វិល 90%វិញនៃបុព្វលាភតាមអត្រាសមាមាត្ររយៈពេលកិច្ចសន្យាដែលនៅមានសុពលភាព ចំពោះករណីមិនមានការទាមទារសំណងធានារ៉ាប់រងត្រូវបានធ្វើឡើង។